# ការបង្កើនចំណេះដឹងរបស់អ្នក
# ស្ដីពីការដាំដុះដំណាំស្រូវ

(កំណែលើកទី២)

គម្រោងបង្កើនផលិតភាពកសិកម្មក្នុងតំបន់ទន្លេសាបប៉ែកខាងលិច
(APPP)

©Japan International Cooperation Agency

# សំរាប់អ្នកប្រើប្រាស់

សៀវភៅមគ្គុទេសក៍ត្រូវបានរៀបរៀងឡើងដោយគម្រោងបង្កើនផលិតភាពកសិកម្មក្នុងតំបន់ទន្លេសាបប៉ែកខាងលិច(APPP)សហការអនុវត្តន៍ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)ក្នុងប្រទេសកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) សំរាប់ជាប្រយោជន៍បន្ថែមចំពោះប្រជាកសិករខ្មែរ និងស្ថាប័នពាក់ព័ន្ធទាំងអស់ដើម្បីជួយបង្កើនចំណេះដឹង និងសមត្ថភាពបច្ចេកទេសរបស់ពួកគាត់ក្នុងការដាំដុះដំណាំស្រូវ។

មិនដូចសៀវភៅលំហូរបច្ចេកទេសធម្មតាផ្សេងទៀតទេ សៀវភៅមគ្គុទេសក៍នេះគឺចងក្រងឡើងជា"សៀវភៅដែលស្តែងនូវបញ្ហាជាក់លាក់"សំរាប់ញាំងឲ្យប្រជាកសិករនូវគំនិត និងមធ្យោបាយដ៏ត្រឹមត្រូវក្នុងការអនុវត្តន៍ការដាំដុះដំណាំស្រូវដោយផ្អែកលើទ្រឹស្តីក្សេត្រសាស្រ្តនៃបច្ចេកទេសនិមួយៗ។

ជំពូកទី១គឺបញ្ចូលទាំងចំណេះដឹងជាមូលដ្ឋានគ្រឹះផ្តល់ជូនជាពិសេសដល់ប្រជាកសិករ និងជំពូកទី២គ្របដណ្តប់ទាំងផ្នែកនៃជំនាញការក្សេត្រសាស្រ្តសំរាប់មន្រ្តី ឬបុគ្គលិកដែលមានមុខងារជាអ្នកបង្រៀនផ្នែកកសិកម្មដល់កសិករ។

យើងខ្ញុំសូមជូនពរដល់ប្រជាកសិករ និងស្ថាប័នពាក់ព័ន្ធទាំងអស់ដែលទទួលសៀវភៅមគ្គុទេសក៏នេះទទួលបាននូវភាពជោគជ័យក្នុងការអភិវឌ្ឍចំណេះដឹង និងសមត្ថភាពបច្ចេកទេសប្រយោជន៍ដើម្បីផលិតស្រូវមានគុណភាពឲ្យបានច្រើនប្រកបដោយទិន្នផលខ្ពស់។

គម្រោងបង្កើនផលិតភាពកសិកម្មក្នុងតំបន់ទន្លេសាបប៉ែកខាងលិច(APPP)

**អ្នកនិពន្ធ**: លោក សាតូរុ ហាហ្គីវ៉ារ៉ា ប្រធានទីប្រឹក្សាគម្រោង / JICA

(*រូបភាពទំព័រគម្របដោយ : Mr Shinnichi Kuno /JICA )

# ជំពូក ១

# មូលដ្ឋានគ្រឹះសំរាប់ការដាំដុះដំណាំស្រូវ



# -ខ្យល់ចេញចូលមិនល្អ-





# - ខ្យល់ចេញចូលបានល្អ -

ខ្យល់ចេញចូលល្អក្នុងស្រែគឺជាកត្តាដ៏ចាំបាច់ចំពោះការមិន
បង្កបរិយាកាសល្អសំរាប់ភ្នាក់ងារជំងឺផ្សេងៗ



# - ការរាំងស្ទះពន្លឺព្រះអាទិត្យដោយសារស្មៅ-



# - ពន្លឺព្រះអាទិត្យក្រោមការសំអាតស្មៅបានល្អក្នុងស្រែ -



# ស្មៅជាជំរកនៃមេរោគ ពពួកជំងឺផ្សិត និងកត្តាចង្រៃផ្សេងៗ

ស្មៅជាជំរកដ៏សុខសាន្តនៃមេរោគ ពពួកជំងឺផ្សិត
និងកត្តាចង្រៃផ្សេងៗសំរាប់ការវិវត្តន៍កូនចៅរបស់ពួកគេ។



“**ការសំអាតស្មៅ**”គឺជាការអនុវត្តគ្រឹះ និងបឋមដែលចាំបាច់ដោយខានពុំបានសំរាប់ការគ្រប់គ្រងកត្តាចង្រៃផ្សេងៗ



# គំរូនៃការអនុវត្តការសំអាតស្មៅបានល្អ




ចូរសំអាតស្មៅទាំងអស់គ្នាដើម្បីជួយឲ្យ
ដំណាំស្រូវលូតលាស់មានសុខភាពល្អ
និងបន្ថយការបាត់បង់នៃជីវជាតិដី។
photolibrary

# ដង់ស៊ីតេដំណាំ និងប្រសិទ្ធភាពនៃការដាក់ជី(១)



# ដង់ស៊ីតេដំណាំ និងប្រសិទ្ធភាពនៃការដាក់ជី (ការពន្យល់បន្ថែម) (២)





# ត្រូវប្រាកដថាដីស្រែរៀបចំបានស្មើតាមតែអាចធ្វើទៅបានដើម្បីធានានូវការលូតលាស់ស្មើៗគ្នា



# - ការសន្សំសម្ចៃថវិកាដោយការសំអាតស្មៅ -



# តើសំណាបមួយណារងផលខូចខាតខ្លាំង?



# ការបាចជី


UREA
46-0-0


NPK
18-46-0
18-8-8
18-8-8+TE
20-20-15+TE


សមាសភាព
NPK 4-3-3 + 1MgO
European Union

# ល័ក្ខខ័ណ្ឌស្រែចាំបាច់សំរាប់ការដាក់ជី





**ពេលគ្មានទឹកក្នុងស្រែ ចូរកុំបាចជីឲ្យសោះ**

* ជីនឹងមិនរលាយចូលក្នុងដីទេ ប្រសិនបើគ្មានទឹក ហើយឫសក៏មិនអាចស្រូបយកជីជាតិបានយ៉ាងមានប្រសិទ្ធភាពដែរ។ លើសពីនេះ សមាសធាតុជីនឹងហើរចេញទៅតាមខ្យល់ក្នុងល័ក្ខខ័ណ្ឌដីស្ងួត។



# ជីសរីរាង្គ (ជីកំប៉ុស្តិ៍)



- ការដាំដុះតាមបែបសរីរាង្គគឺត្រូវការដាក់ជីកំប៉ុស្តិ៍(កែច្នៃបានល្អ)ឲ្យបានច្រើន
- រូបភាព(ខាងស្តាំ)បង្ហាញលក្ខខណ្ឌនៃការកែច្នៃជីកំប៉ុស្តិ៍បានល្អដោយត្រូវចំណាយពីរទៅបីខែដើម្បីកែច្នៃ។
- ចំនួនជីកំប៉ុស្តិ៍ក្នុងរូបភាពអាចបាចបានត្រឹមតែ ០.៥ហ.តនៃផ្ទៃដីស្រែប៉ុណ្ណោះ។




ជីលាមកសត្វ និងជីកំប៉ុស្តិ៍ត្រូវបាចឲ្យបានស្មើគ្របដណ្តប់ពាសពេញផ្ទៃស្រែដើម្បីបញ្ចៀសការលូតលាស់មិនស្មើគ្នា។



ការដាំដុះតាមបែបសរីរាង្គត្រូវចំណាយជីកំប៉ុស្តិ៍ពី ៥-១០តោន/ហ.ត ហើយតម្រូវឲ្យដាក់ជារៀងរាល់ឆ្នាំ។

# ជីសរីរាង្គ (ជីកំប៉ុស្តិ៍ជាមួយលាមកគោក្របី)

## របៀបកែច្នៃ



លាយជាមួយចំបើង ឬអង្កាម ហើយស្រោចទឹកតិចៗដើម្បី ទទួលបានល័ក្ខខ័ណ្ឌសំណើម ល្អ។



គ្របកៅស៊ូប្លាស្ទិក ឬសម្ភារៈផ្សេងទៀតដែលអាចការពារភ្លៀងបាន។



បន្ទាប់ពី៣-៤សប្តាហ៍ ច្របល់ឲ្យបានល្អ ហើយ រក្សាទុករយៈ៤-៥សប្តាហ៍ទៀត។ ត្រូវច្របល់ម្តងម្កាលរហូតជីកំប៉ុស្តិ៍ឡើង ម៉ត់ដូចដីខ្សាច់។



(មិនត្រូវបានណែនាំ) លាមកគោក្របីស្រស់ ដោយកែច្នៃតិចតួច។

(ត្រូវបានណែនាំ) កែច្នៃបានល្អ រហូតម៉ត់ដូចដីខ្សាច់។

# នៅពេលណា និងចំនួនជីសរីរាង្គប៉ុន្មាន(លាមកសត្វ)ដែលគួរបាច?






- កំរិតអាសូត(N)ស្ថិតលំដាប់ពី១%ដល់៣%។ កម្រិតហ្វូសហ្វ័រ(P) & ប៉ូតាស្យូម(K)ស្ថិតលំដាប់ពី១%ដល់៦% អាស្រ័យលើប្រភេទលាមកសត្វ(គោ ជ្រូក មាន់)។ →មើលទំព័រទី48។
- ដើម្បីផ្តល់ជាតិ(N.) គឺស្មើនិង១ការ៉ុង(៥០គ.ក្រ) នៃជីដេអាប៉េ (N=១៨%), ជុំវិញ២៥០គ.ក្រនៃអាចម៍សត្វត្រូវបាចលើផ្ទៃដីមួយហិចតា។
  នៅពេលផ្តល់ជាតិ(N) គឺស្មើនិងជីអ៊ុយរ៉េ(N=៤៦%) ៥៥០គ.ក្រនៃអាចម៍សត្វតម្រូវឲ្យបាចលើផ្ទៃដីមួយហិចតា។








**ដំណាក់កាលលូតលាស់ខ្ចី**

- សារធាតុចិញ្ចឹមរបស់ដីត្រូវបានស្រូបយកដើម្បីសាងសង់ដើមដងដំណាំ (= បង្កើនចំនួនដើមក្នុងគុម្ពច្រើន )

**ដំណាក់កាលពហុផលិត/បន្តពូជ**

- មិនបង្កើនចំនួនដើមទេក្នុងដំណាក់កាលនេះ។
- សារធាតុចិញ្ចឹមរបស់ដីត្រូវបានស្រូបជាចម្បងប្រើសំរាប់លូតលាស់កួរ និងធ្វើឲ្យគ្រាប់ធំធាត់ល្អ។

# របៀបបាចជីលាមកសត្វ ធ្យូងអង្កាម









ស្រូវលូតលាស់មិនស្មើ
(គំរូមិនល្អ)



ស្រូវលូតលាស់ស្មើគ្នា
(គំរូល្អ)



★លាមកសត្វ និងធ្យូងអង្កាមគួរតែព្រោះអោយបានស្មើលើផ្ទៃដីស្រែដូចក្នុងរូបភាពដែលបានបង្ហាញខាងស្តាំ។

★គំនរជីលាមកសត្វបន្សល់ក្នុងស្រែដោយពុំបានបាចពង្រាយឲ្យសព្វផ្ទៃដីស្រែទាំងមូលនិងនាំមកនូវភាពលូតលាស់មិនស្មើគ្នារបស់ដំណាំស្រូវ។ បន្ទាប់មកវានាំឲ្យកួរស្រូវទំុមិនស្មើគ្នាដែរ បណ្តាលឲ្យគុណភាពស្រូវទាបនៅពេលលក់។



# - ការគ្រប់គ្រងកត្តាចង្រៃ -



# វិធានការសំរាប់ការគ្រប់គ្រងកក្កាចង្រៃ និងសត្វល្អិត

## សកម្មភាពដ៏មានប្រសិទ្ធភាពចម្បងៗបួន(4)ដើម្បីកាត់បន្ថយជំងឺ និងសត្វល្អិតមិនមានប្រយោជន៍

| | | | |
|---|---|---|---|
|  |  |  |  |
| **ការដុតបំផ្លាញកាកសំណល់**<br>*ការដុតទាំក្នុង និងក្រៅស្រែជាការអនុវត្តល្អបំផុតដើម្បីដុតកំទេចចោលសំបុកនៃធាតុបង្កជំងឺ និងពងសត្វល្អិត។ | **ការធ្វើប្រព្រឹត្តិកម្មពូជដោយសម្លាប់មេរោគ**<br>*ការសម្លាប់មេរោគដោយត្រាំពូជក្នុងទឹកក្តៅនូវសីតុណ្ហភាព៦០អង្សាររយៈពេល១០នាទីគឺមានប្រសិទ្ធខ្ពស់នៅដំណាក់លូតលាស់ដំបូង។ | **ការសំអាតស្មៅក្នុងស្រែ និងតាមភ្លឺ**<br>* គោលបំណងមួយនៃការសំអាតស្មៅនោះគឺកំចាត់សំបុកនៃធាតុបង្កជំងឺ(ពពួកផ្សិត បាក់តេរី វីរុស) និងពងសត្វល្អិតដើម្បីទប់ស្កាត់ការវិវឌ្ឍន៍ច្រើនរបស់ពួកវា។ | **ការបាញ់ថ្នាំគីមី**<br>(ថ្នាំសម្លាប់កក្កាចង្រៃ ថ្នាំសម្លាប់សត្វល្អិត)<br>*បាញ់ថ្នាំគីមីគួរតែវិធានការចុងក្រោយបំផុត។ |

**អត្ថបទគន្លឹះអំឡុងពេលដាំដុះដំណាំស្រូវ → “<u>ឆាប់រកឃើញ និងឆាប់ចាត់វិធានការ</u>”**

ចូរកុំខកខាននូវរោគសញ្ញាដំបូងនៃការចម្លងរោគដោយសង្កេតស្រែជាប្រចាំឲ្យបានដិតដល់!!



→

កំណត់ជំងឺ និងសត្វល្អិតដោយពិនិត្យតាមសៀវភៅបច្ចេកទេសនេះ!!



# ប្រសិទ្ធភាពនៃការដុតគល់ជញ្ជ្រាំង និងស្មៅក្នុងស្រែ និងតាមភ្លឺ

## ប្រសិទ្ធផលជាវិជ្ជមាន

ករណីស្រែបានទទួលរងធ្ងន់ធ្ងរដោយជំងឺស្រូវ និងកក្កាចង្រៃនៅរដូវកាលដាំដុះកន្លងមក ការដុតកំទេចគល់ជញ្ជ្រាំង និងស្មៅងាប់ក្នុងស្រែ និងតាមភ្លឺជាការណែនាំខ្លាំងបំផុតដើម្បីបញ្ចៀសការរីករាលដាលនូវជំងឺស្រូវ និងកក្កាចង្រៃនៅរដូវដាំដុះបន្ទាប់ទៀត។

ប្រសិទ្ធផលជាវិជ្ជមានសំរាប់ការដុតជញ្ជ្រាំង:

①សម្លាប់ប្រភពបង្កជំងឺ និងពងសត្វល្អិតដែលកំពុងរស់នៅក្នុងគល់ជញ្ជ្រាំង និងស្មៅបន្ទាប់ពីច្រូតកាត់រួច។ (←ប្រសិទ្ធផលសំខាន់បំផុត)

②ផេះអាចផ្តល់នូវសារធាតុប៉ូតាស្យូម.




## ប្រសិទ្ធផលជាអវិជ្ជមាន

● *បាត់បង់សម្ភារៈសរីរាង្គ (ដើមស្រូវស្ងួតដូចជាចម្បើង)។*

● *សម្លាប់បាក់តេរីមីក្រូសរីរាង្គក្នុងស្រែទាប់ផ្ទៃដី។*

ករណីពុំមានការកើតឡើងនូវជំងឺស្រូវ និងកក្កាចង្រៃដែលរីករាលធ្ងន់ធ្ងរនៅរដូវកាលដាំដុះកន្លងមកនោះទេ គល់ជញ្ជ្រាំងមិនចាំបាច់ដុតនោះទេ ហើយគួរច្របល់ក្នុងដីតាមរយៈការភ្ជួររាស់ភ្លាមៗបន្ទាប់ពីច្រូតកាត់រួចក្រោមលក្ខខណ្ឌដីមានសំណើម ដើម្បីពន្លឿនការធ្វើឲ្យឆាប់រលួយនៃសំបើងក្នុងចន្លោះរដូវកាលដាំដុះ។



# ប្រភេទថ្នាំគីមីកសិកម្មសំរាប់ដំណាំស្រូវ

## ថ្នាំសំលាប់សត្វល្អិត

**ដើម្បីសំលាប់សត្វល្អិត ស្រឹង និងដង្កូវ**



| សត្វល្អិត និងដង្កូវចម្បងៗ | ថ្នាំគីមីដែលអាចប្រើបាន |
|---|---|
| • ដង្កូវហ្វូង → | ណាតូ/NATO 55EC (សារធាតុរាវ) |
| • មមាចត្នោត → | ណាតូ/NATO 55EC/ ACTION 5SC(សារធាតុរាវ) |
| • មមាចបៃតង → (*ជំងឺទុងគ្រោប្រភពចម្លងវីរុស) | អ៊ែកសិន/ACTION 5SC (សារធាតុរាវ) |
| • ដង្កូវមូរស្លឹក → | ណាតូ/NATO 55EC(សារធាតុរាវ) |
| • ស្រឹងស្រូវ → | ថ្នាំសំលាប់សត្វល្អិតមិនទាន់បានកំណត់។ |
| • ដង្កូវស៊ីរូងដើមពណ៌លឿង → | អ៊ែកសិន/ACTION 5SC (សារធាតុរាវ) |
| • ទ្រីបស្រូវ → | ថ្នាំសំលាប់សត្វល្អិតមិនទាន់បានកំណត់។ |

## ថ្នាំកំចាត់ពពួកជំងឺផ្សិត

**ដើម្បីសំលាប់ "បាក់តេរី ពពួកផ្សិត"**



| ជំងឺចម្បងៗ | ថ្នាំគីមីដែលអាចប្រើបាន |
|---|---|
| ●ជំងឺប្លាស់ → | សាវន្ត/ SAWANT 400EC (សារធាតុរាវ) |
| ●ជំងឺរលាកស្លឹក → | ថ្នាំកំចាត់ពពួកផ្សិតមិនទាន់បានកំណត់។ |
| ●ជំងឺធ្យូងបៃតង → | ថ្នាំសំលាប់សត្វល្អិតមិនទាន់បានកំណត់។ |

## ថ្នាំកំចាត់ស្មៅ

**ដើម្បីកំចាត់ស្មៅ និងរុក្ខជាតិផ្សេងៗ (មានជម្រើស)**



ថ្នាំគីមីទាំងអស់សុទ្ធតែមានសារធាតុពុល
ដល់មនុស្ស សត្វពាសបហានៈ និងត្រី។
"គ្រោះថ្នាក់"!!

# តើត្រូវបាញ់ថ្នាំគីមីរបៀបណា និងនៅពេលណា?

ល្អ




មិនល្អ



# ថ្នាំគីមីកសិកម្មគ្រប់ប្រភេទសុទ្ធតែ "មានសារធាតុពុល" ដល់មនុស្ស និងសត្វពាហនៈ

**អ្នកត្រូវតែការពារខ្លួនរបស់អ្នកពី**

**ជាតិពុល!!**




## -គ្រោះថ្នាក់-

នៅពេលបាញ់ថ្នាំគីមី ;

- ខ្លួនប្រាណទាំងមូលត្រូវគ្របដណ្តប់ដូចបានបង្ហាញរូបភាពនៅខាងឆ្វេង។
- បន្ទាប់ពីបាញ់ថ្នាំរួចរាល់ ចូរកុំពិសារស្រា ឬភេសជ្ជៈដែលមានជាតិអាល់កុលដែលអាចបន្ថែមហានិភ័យដល់សារពាង្គកាយ ជាហេតុធ្វើឲ្យរាង្គកាយរបស់អ្នកមិនប្រក្រតី។

# របៀបរៀបចំល្បាយថ្នាំគីមី (ករណីថ្នាំ "សាវន្ត / SAWANT")




ខាងឆ្វេង (250ម.ល), ខាងស្តាំ(500ម.ល)

ឈ្មោះថ្នាំគីមី : សាវន្ត / SAWANT

ប្រភេទថ្នាំគីមី : ថ្នាំកំចាត់ពពួកផ្សិត:

ទីសដៅ : *ជំងឺផ្សិតស្រូវ ឬជំងឺប្លាស់"

## គ្រោះថ្នាក់

- វាជាទង្វើមួយខុសស្គងដែលគិតថា "ដង់ស៊ីតេល្បាយកាន់តែខ្ពស់ កាន់តែមានប្រសិទ្ធភាព "
- ចូរកុំបាញ់ថ្នាំ២សប្តាហ៍មុនពេលច្រូតកាត់ឲ្យសោះ។

ថ្នាំសាវន្ត1ដប
ចំណុះ (250ម.ល)

ទឹកថ្លា
(130ល)

ចំនួនកំហាប់ល្បាយ (130ល)
អាចបាញ់បានលើផ្ទៃដី
0.5ហ.ត




### -គ្រោះថ្នាក់-

សេចក្តីណែនាំដែលបានសរសេរនៅលើដបនិយាយថា ថ្នាំគីមី ៧៥ម.លលាយជាមួយទឹក២០លីត្រ។

<u>យ៉ាងណាមិញ វាពិតជាច្រើនណាស់ ហើយប្រហែលជាផ្តល់ដល់ស្រូវដែលត្រូវបានបំផ្លាញផងដែរ</u>។ ដូច្នេះ អត្រាល្បាយក្នុងក្រឡេននេះ (អត្រាល្បាយគឺ៥០០ដង)គឺត្រូវបានណែនាំដើម្បីបញ្ចៀសការបំផ្លិច បំផ្លាញលើដំណាំស្រូវ។

# របៀបរៀបចំល្បាយថ្នាំគីមី(ករណីថ្នាំ"អ៊ែកសិន/ACTION 5SC")



ថ្នាំទាំងពីរនេះជាផលិតផលដូចគ្នា

(250ml)



ឈ្មោះថ្នាំគីមី: អ៊ែកសិន/ACTION 5SC

ប្រភេទថ្នាំគីមី:   ថ្នាំសំលាប់សត្វល្អិត

គោលដៅ : សត្វល្អិត និងដង្កូវ

(*<u>ដង្កូវស៊ីរូងដើមពណ៌លឿង  មមាចត្នោត មមាចបៃតង ដង្កូវមូរស្លឹក)</u>

<u>គ្រោះថ្នាក់</u>

- អត្រាល្បាយទឹកថ្នាំជាក់លាក់ត្រូវតែកំណត់ទៅតាមការសរសេរណែនាំលើស្លាកដប។
- **វាជាទង្វើមួយខុសស្តងដែលគិតថា  <u>"ដង់ស៊ីតេល្បាយកាន់តែខ្ពស់ កាន់តែមានប្រសិទ្ធភាព "</u>**
  ត្រូវប្រាកដថាធ្វើតាមការណែនាំពីអត្រាលាយទឹក (ល្បាយទឹក)។
- ចូរកុំបាញ់ថ្នាំ២សប្តាហ៍មុនពេលច្រូតកាត់ឲ្យសោះ។







**-គ្រោះថ្នាក់-**

អត្រាល្បាយ (ថ្នាំគីមី និងទឹក)គឺខុសគ្នាអាស្រ័យលើប្រភេទថ្នាំគីមី។ ត្រូវអានសេចក្តីណែនាំដែលបានសរសេរលើដបយ៉ាងប្រុងប្រយត្ន។

# ជំងឺស្រូវ





# "ជំងឺប្លាស់" និងថ្នាំគីមីដែលអាចប្រើប្រាស់បាន-(1)



# “<u>ជំងឺធ្លាស់</u>” និងថ្នាំគីមីដែលអាចប្រើប្រាស់បាន-(2)










<u>ភ្នាក់ងារចម្លង</u>: **ពពួកផ្សិត**
<u>ដំណាក់កាលដែលអាចចម្លងជំងឺ</u>: ដំណាក់កាលសំណាប ដំណាក់កាលលូតលាស់បែកគុម្ព ដំណាក់កាលចេញកួររហូតដល់ទុំ។
<u>ថ្នាំគីមីដែលប្រើប្រាស់បាន</u>: (សាវន្ត) SAWANT 400EC, (ប្លាស់) Flash75WP, (សាកាតា) SAKATA 500SC, (សាណាសា) SANASA 100SC, (តាណាសា) TANAXA 700 WP,(កាបិនស៊ីម) CABENZIM 500FL”

<u>រយៈពេលនៃការបាញ់ថ្នាំ និងការអង្កេតមើល</u>:
- ចាប់ផ្តើមមានការឆ្លង ⇒ **បាញ់ថ្នាំមួយដង**
- ករណីមានការឆ្លងធ្ងន់ធ្ងរ
  ⇒ **បាញ់ថ្នាំមួយដងក្នុងមួយសប្តាហ៍ × 2សប្តាហ៍**
  *ចំណាយពេលពី៦-៧ថ្ងៃចន្លោះនៃការបាញ់ថ្នាំលើកទី១ និងលើកទី២ ហើយ អង្កេតយ៉ាងយកចិត្តទុកដាក់ពីរោគសញ្ញារបស់ស្លឹកបន្ទាប់ពីបាញ់រួច។
- មិនត្រូវបាញ់ថ្នាំគីមីក្នុងអំឡុងពេល២សប្តាហ៍មុនការប្រមូលផលនោះឡើយ។

***កត្តាអំណោយផលដែលធ្វើឲ្យជំងឺមានការរីវឌ្ឍ និងរាលដាលបានលឿន**

- ពូជស្រូវមិនធន់⇒ **<u>ផ្ការំដួល</u>**
- **<u>ប្រើប្រាស់ពូជដែលមានសត្វចង្រៃ និងជំងឺ</u>**
- ប្រើប្រាស់ជី**អាសូត**លើសចំនួន
- **<u>មានរុក្ខជាតិតូចៗ និងស្មៅ</u>**ច្រើនក្នុង និងជុំវិញផ្ទៃដីស្រែ
- គ្មានលំហូរខ្យល់ និងមានពន្លឺព្រះអាទិត្យចាក់ចូលតិចតួចនៅផ្នែកខាងក្រោមនៃដើម។
- ថ្ងៃមានភ្លៀងធ្វើឲ្យមានសំណើមក្នុងខ្យល់ខ្ពស់

# ជំងឺធ្យូងបៃតង







ភ្នាក់ងារចម្លង: **ពពួកផ្សិត** (=ស្ព័រ)

*កើតមាននៅលើកួរស្រូវប៉ុណ្ណោះ

*ស្ព័រអាចរស់បាននៅលើដី និងឆ្លងទៅដំណាំថ្មីក្នុងរដូវកាលដាំដុះបន្ទាប់

ការបំផ្លិចបំផ្លាញ: បង្កើនគ្រាប់ស្រូវស្អក (គ្មានគ្រាប់)

ប្រភេទថ្នាំគីមី: **ថ្នាំកំចាត់ពពួកផ្សិត**

**(ថ្នាំកំចាត់ពពួកផ្សិតមិនទាន់បានកំណត់នៅឡើយ)**

វិធានការ:

ដកកួរដែលបានឆ្លងចោលដោយដៃនៅពេលដែលឃើញមាននៅក្នុងស្រែ។

**កត្តាអំណោយផលដែលធ្វើឲ្យជំងឺមានការវិវឌ្ឍ និងរីករាលដាលបានលឿន**

● ប្រើប្រាស់ជី**អាសូត**លើសចំនួន

● ដាក់ជី**អាសូត** (បំប៉ន)នៅដំណាក់កាលចុងក្រោយនៃការលូតលាស់ (បន្ទាប់ពីចេញកួរ)

● សំណើមខ្ពស់ (ភ្លៀងច្រើន)

# ជំងឺរលាកស្លឹក





ភ្នាក់ងារចម្លង: ពពួកមេរោគដែលបង្កដោយបាក់តេរី

ដំណាក់កាលដែលអាចចម្លង: ដំណាក់កាលលូតលាស់បែកគុម្ព, ដំណាក់កាលចេញកួរ

ថ្នាំគីមីដែលអាចប្រើប្រាស់បាន:

**ថ្នាំគីមីដែលអាចប្រើប្រាស់បានគឺពុំទាន់បានកំណត់នៅឡើយ។**

វិធីសាស្រ្តការពារដែលមានប្រសិទ្ធភាព:

⇒**សំអាតស្មៅឲ្យបានទៀងទាត់នៅតាមប្រឡាយធារាសាស្រ្ត**

***កត្តាអំណោយផលដែលធ្វើឲ្យជំងឺមានការអភិវឌ្ឍន៍ និងបង្កើតជាថ្មីបានលឿន**

●មានរុក្ខជាតិតូចៗ និងស្មៅច្រើននៅក្នុង និងជុំវិញផ្ទៃដីស្រែ

●ប្រើប្រាស់ជីលើសចំនួន

●គល់កញ្រ្ជាំងដែលបានចម្លងជំងឺ

●មានបាក់តេរីក្នុងស្រែ និងតាមប្រឡាយធារាសាស្រ្ត

●សីតុណ្ហភាពខ្ពស់ មានសំណើមខ្ពស់ មានភ្លៀង ជំពៅទឹកជ្រៅ និងមានទឹកជំនន់។

a

# សត្វល្អិត & ដង្កូវ







# ដង្កូវស៊ីរូងដើមពណ៌លឿង(១)









ស្រូវត្រូវបានវាយប្រហារដោយសត្វល្អិតធ្វើឲ្យស្រពោន និងប្រែក្លាយ
ជារល្វ៉យដើម ឬកួរពណ៌ស។
ករណីបំផ្លាញធ្ងន់ធ្ងរ កួរពណ៌សនិងស្ដែងឲ្យឃើញកាន់តែច្រើន។
<u>សត្វល្អិតញីអាចផ្ទុកបាន៣០០ពងនៅក្នុងអូវ៉ែរ។</u>

# ដង្កូវស៊ីរូងដើមពណ៌លឿង ( ២ )










<u>ថ្នាំគីមីដែលអាចប្រើប្រាស់បាន:</u> **អ៊ែកសិន /ACTION 5SC** (យោងតាមប្រភេទផ្សេងទៀតនៅលើទំព័រទី43)

<u>រយ:ពេលនៃការបាញ់ថ្នាំ និងការអង្កេតមើល:</u>

● ចាប់ផ្តើមមានការឆ្លង ⇒ បាញ់ថ្នាំ**១ដងក្នុងមួយសប្តាហ៍**

● ករណីជំងឺឆ្លងមានសភាពធ្ងន់ធ្ងរ ⇒ **បាញ់ថ្នាំ១ដងក្នុងមួយសប្តាហ៍ × 2 សប្តាហ៍**

*ចំណាយពេលពី៦-៧ថ្ងៃចន្លោះនៃការបាញ់ថ្នាំលើកទី១ និងលើកទី២ ហើយត្រូវពិនិត្យឲ្យបានដិតដល់ពីរោគសញ្ញាលើស្លឹកជារៀងរាល់ថ្ងៃបន្ទាប់ពីបាញ់លើកទី១រួច។

**កត្តាអំណោយផលដែលធ្វើឲ្យសត្វល្អិតមានការវិវឌ្ឍ**

● មានរុក្ខជាតិតូចៗ និងស្មៅជាច្រើននៅក្នុង និងជុំវិញផ្ទៃដីស្រែ។

● គល់ជញ្ជ្រាំងសល់នៅក្នុងស្រែ។

# មមាចត្នោត









ថ្នាំគីមីដែលអាចប្រើប្រាស់បានៈ ①(អ៊ែកសិន) ACTION 5SC, ②(ណាតូ) NATO 55EC

របៀបប្រើ: អានតាមការណែនាំនៅទំព័រទី 25

ការបាញ់ថ្នាំ: នៅពេលដែលឃើញមមាចត្នោតតិចតួច សូមប្រញាប់បាញ់ថ្នាំជាបន្ទាន់។

***កត្តាអំណោយផលដែលធ្វើឲ្យសត្វល្អិតមានការរីវឌ្ឍ**

- មានស្មៅច្រើន
- ល័ក្ខខ័ណ្ឌនៃការបន្តជាំទឹក (**កំរិតទឹកខ្ពស់** )នៅក្នុងស្រែ
- ម្លប់ និងសំណើមខ្ពស់ដោយសាររុក្ខជាតិតូចៗ ឬស្មៅច្រើន
- ប្រើប្រាស់សារធាតុអាសូតលើសចំណុះ
- មមាចនិងរីករាលដាលកាន់តែច្រើនបន្ទាប់ពីដំណាក់កាលកំណរកំណើតកូរ។

# ទ្រីបស្រូវ





- ទ្រីបស្រូវស៊ីចំណីនៅលើស្មៅស៊ុបទ្រប់ ហើយពេញវ័យ និងកូនតូចរស់នៅលើភ្លឺ និងវាលស្រែបន្ទាប់ពីច្រូតកាត់រួច។
- សត្វល្អិតប្រភេទនេះវាយប្រហារជាពិសេសនៅដំណាក់សំណាបខ្ចី។ ជួនកាលវាយប្រហារស្រូវក្នុងស្រែបន្ទាប់ពីស្ទូងរួច។
- បន្ទាប់ពីវាយប្រហាររួច ស្លឹកស្រូវប្រែក្លាយជាស្រពោនម្ចូរចុះ និងមានគ្រាប់ស្រូវស្ញៀត។



ការបំផ្លាញ: -វាជញ្ជក់ជាអាហារនៅដំណាក់កាលស្រូវខ្ចី។
-ធ្វើឲ្យគ្រាប់ស្រូវមានអុចខ្មៅ និងថយចុះគុណភាពជាគំហុក។

ថ្នាំគីមីអាចប្រើប្រាស់បាន: ACTION 5SC ,   DIAZAN 50 EC,   DIAPHOS 10 H

របៀបប្រើប្រាស់ថ្នាំគីមី: សូមមើលទំព័រទី 24

កត្តាអំណោយផលដែលធ្វើឲ្យសត្វល្អិតមានការរីវឌ្ឍលឿន

- អាកាសធាតុស្ងួតក្តៅ
- ពុំមានទឹកជាប្រចាំ
- វត្តមាននៃប្រភេទរុក្ខជាតិ និងស្មៅជាលក្ខណ:ធុញ្ញជាតិ។

# មមាចបៃតង












ថ្នាំគីមីអាចប្រើប្រាស់បាន
ACTION 5SC

ការបំផ្លិញបំផ្លាញៈ

- រស់ដោយការជញ្ជក់រុក្ខរសរបស់ដំណាំនៅដំណាក់កាលលូតលាស់ចុងក្រោយ។
- មមាចបៃតងនិងចម្លង **ជំងឺវីរុស**ដូចជាជំងឺទុងគ្រោ ជំងឺតឿពណ៌លឿង។ល។

● *ករណីដំណាំស្រូវបានឆ្លងជំងឺវីរុស ប្រភេទថ្នាំគីមីផ្សេងៗ(ដែលមានធាតុផ្សំភ្នាក់ងារថ្នាំគីមី សម្លាប់វីរុស)ត្រូវតែបាញ់ជាបន្ទាន់។ (*ថ្នាំគីមីកំចាត់វីរុសប្រហែលជាពុំមានទេក្នុងប្រទេសកម្ពុជា)*

● ពេលវេលានៃការដាំដុះស្របគ្នា ឬប្រហាក់ប្រហែលគ្នាជាមធ្យោបាយមួយដើម្បីបញ្ចៀសមមាចដែរ។

## កត្តាអំណោយផលដែលធ្វើឲ្យសត្វល្អិតមានការរីកលូតលាស់លឿន

●**មានរុក្ខជាតិតូចៗ និងស្មៅច្រើន**នៅក្នុងស្រែ និងជុំវិញផ្ទៃដីស្រែ និងតាមប្រឡាយធារាសាស្ត្រ។

●មានភ្លៀងតិច សីតុណ្ហភាពខ្ពស់។

●ប្រើប្រាស់ជី**អាសូត**លើសចំនួន។

# ដង្កូវមូរស្លឹក












ថ្នាំគីមីដែលអាចប្រើប្រាស់បានៈ **ណាតូ NATO 55EC**

* ប្រសិនបើអ្នកឃើញមានដង្កូវមូរស្លឹកក្នុងស្រែរបស់អ្នក យើងសូមណែនាំឲ្យអ្នកហែក និងសម្លាប់ដង្កូវដែលរស់នៅក្នុងស្លឹកមូរនោះចោល។

***កត្តាអំណោយផលដែលធ្វើឲ្យសត្វល្អិតមានការអភិវឌ្ឍន៍**

- មានរុក្ខជាតិតូចៗ និងស្មៅច្រើននៅក្នុងស្រែ និងជុំវិញតាមភ្លឺស្រែ
- មានម្លប់ និងសំណើមខ្ពស់ដោយសាររុក្ខជាតិតូចៗ និងស្មៅច្រើន
- ប្រើប្រាស់ជីលើសចំនួន
- ជាពិសេសលើស្រូវពង្រោះ

# ស្រឹងស្រូវ





prif.chiba.lg.jp



នៅដំណាក់កាលដាក់ទឹកដោះ ស្រឹងជញ្ជក់យកទឹកដោះ
និងបន្សល់ស្នាមអុជខ្មៅនៅលើគ្រាប់ស្រូវជាច្រើន។



ស្រឹងខ្មៅជញ្ជក់ដើមស្រូវ និងបង្អាក់ការ
អភិវឌ្ឍនៃការបែកគុម្ព និងការលូត
លាស់របស់ដើមស្រូវ។

<u>ថ្នាំគីមីដែលអាចប្រើប្រាស់បាន:</u> (អ៊ែកសិន) **ACTION 5SC**

ការបំផ្លិចបំផ្លាញ:

— ស្រឹងទាំងពីរប្រភេទទើបតែកូនញាស់ និងពេញវ័យសុទ្ធតែស៊ីអង់ដូស្ពែម(សាច់គ្រាប់)គ្រាប់ស្រូវជាចំណី ហើយវាធ្វើឲ្យគ្រាប់ស្រូវតូច ស្នាមអុជច្រើន ខូចទ្រង់ទ្រាយ និងប្រែពណ៌។ បន្ទាប់ពីបញ្ហាទាំងអស់នេះកើតឡើងហើយធ្វើឲស្រូវធ្លាក់គុណភាព។

## កត្តាអំណោយផលដែលធ្វើឲ្យសត្វល្អិតមានការអភិវឌ្ឍន៍

- មាន**<u>ស្មៅ និងរុក្ខជាតិតូចៗ</u>**នៅក្នុង និងជុំវិញផ្ទៃដីស្រែច្រើន
- **ស្ទូងតាមទំលាប់**
- អាកាសធាតុអាប់អួរ (មានពពកច្រើន) និងភ្លៀងធ្លាក់ញឹកញាប់
- ដំណាក់កាលស្រូវចេញ និងដាក់ទឹកដោះ។

# តារាងប្រភេទជំងឺ

| ឈ្មោះជំងឺ | | | ថ្នាំគីមីអាចប្រើប្រាស់បាន | |
|---|---|---|---|---|
| Rice Blast |  | ជំងឺប្លាស់ | SAWANT 400EC, CARBENZIM 500FL, SANASA 100SC, TANAXA 700WP, Flash 75WP | សាវន្ត400EC, កាបេនស៊ីម500FL, សាណាសា100SC, តាណាហ្សា700WP , ផ្លាស់75WP |
| (Bacterial) Leaf Blight |  | ជំងឺរលាកស្លឹកដែលបង្ក ឡើងដោយបាក់តេរី | Not identified | ពុំទាន់បានកំណត់ |
| Sheath Blight |  | ជំងឺរលាកស្រទបស្លឹក | SAKATA 500SC, VALIDAN 5SL | សាកាតា500SC, វ៉ាលីដាន5SL |
| Rice Stripe(virus) |  | ជំងឺឆ្នូតស្រូវ (វីរុស) | There is no chemical to control virus directly. Control of Brawn Planthopper (virus transmitter) is the first step, and usable chemicals are as follows.<br>ACTION5SC NATO 55EC, SECSAIGON 25EC, OSIN 50WP | ពុំមានថ្នាំគីមីណាដើម្បីទប់ស្កាត់វីរុសដោយផ្ទាល់បានទេ។ ការទប់ស្កាត់មមាចត្នោត(ភ្នាក់ងារចម្លងវីរុស)គឺជាជំហានដំបូងបង្អស់ និងមានថ្នាំគីមីអាចប្រើប្រាស់បានដូចខាងក្រោមនេះ, អ៊ែកសិន5SC ណាតូ55EC, សិកសៃហ្គុន25EC, អូស៊ីន50WP |

# តារាងថ្នាំកំចាត់សត្វល្អិត

| ឈ្មោះសត្វល្អិត | | ថ្នាំគីមីដែលអាចប្រើប្រាស់បាន | |
|---|---|---|---|
| (English) | (Khmer) | (English) | (Khmer) |
| Rice Army Worm  | ដង្កូវហ្វូង | NATO 55 EC, VITASI 480EC、 ACTION5SC | ណាតូ55 EC, វីតាស៊ី480EC, អូស៊ីន5SC |
| Brawn Planthopper  | មមាចត្នោត | VITASI 480EC, CYRIPHOS 585EC, SECSAIGON10EC, ACTION5SC NATO 55EC, SECSAIGON 25EC, OSIN 50WP, VINO 200SC, NAFAZA 350SC | វីតាស៊ី480EC, ស៊ីរីផូស585EC, សិកសៃហ្គន10EC, អ៊ែកសិន 5SC, ណាតូ55EC, សិកសៃហ្គន25EC, វីណូ200SC, ណាផាហ្សា350SC |
| Green Leafhopper   | មមាចខៀវ | VITASI 480EC, CYRIPHOS 585EC, OSIN 50WP, VIFONE 200SL, NAFAZA 350SC | វីតាស៊ី480EC, ស៊ីរីផូស585EC, អូស៊ីន50WP, វីហ្វូន200SL, ណាផាហ្សា350SC |
| Leaf holder   | ដង្កូវមូរស្លឹក | VICARE 36EC, ALPHAN 5 EC, VITASI 480EC, CYRIPHOS 585EC, SECSAIGON 10EC, SECSAIGON 25EC, CYPENRAN 10EC, DIAZAN 50EC, VINO 200SC, VIGO 500EC, PERAN 50EC, KINALUX 25EC | វីឃែរ36EC, អាល់ហ្វាន5EC, វីតាស៊ី480EC, ស៊ីរីផូស 585EC, សិកសៃហ្គន10EC, សិកសៃហ្គន25EC,ស៊ីប៉េរ៉ង់10EC, ឌីអាហ្សាន50EC, វីណូ200SC , វីហ្គោ500EC,ប៉េរ៉ង់ 50EC, គីណាលុច25EC, |
| Rice Bugs   | ស្រឹងស្រូវ | CYRIPHOS 585EC, SECSAIGON 10EC, SECSAIGON 25EC, OSIN 50WP, VINO 200SC, NAFAZA 350SC | ស៊ីរីផូស 585EC, សិកសៃហ្គន10EC, សិកសៃហ្គន25EC, អូស៊ីន50WP, វីណូ200SC, ណាផាហ្សា350SC |
| Rice Case Worm  | ដង្កូវបំពង់កាត់ស្លឹក | CYPENRAN 10EC , VITASI 480EC, VIGO 500EC, KINALUX 25EC | វីតាស៊ី480EC, ស៊ីប៉េរ៉ង់10EC, វីហ្គោ500EC, គីណាលុច25EC |
| Yellow Stem Borer  | ដង្កូវស៊ីរូងដើមពណ៌លឿង | NATO 55EC, GOLDEN DRAGON 585EC, CYRIPHOS 585EC, CYPENRAN 10EC, DIAZAN 50EC, DIAPHOS 10H, NETOXIN 18SL, PERAN 50EC | ណាតូ55EC, ហ្គោលដិនដ្រាហ្គន585EC, ស៊ីរីផូស585EC,ស៊ីប៉េរ៉ង់10EC,ឌីអាហ្សាន50EC,ឌីអាហ្សាន10H, ណេតូស៊ីន10H, ប៉េរ៉ង់50EC, ឌីអាហ្វូស10H, ណេតូស៊ីន18SL, ប៉េរ៉ង់50EC |
| Rice Thrips   | ទ្រីបស្រូវ | DIAZAN 50 EC, DIAPHOS 10 H | ឌីអាហ្សាន50EC, ឌីអាហ្វូស10H |

# ថ្នាំកំចាត់ស្មៅ( សម្លាប់ស្មៅ)





# ថ្នាំកំចាត់ស្មៅអាចបំផ្លាញដល់ដំណាំស្រូវ





ល្បាយថ្នាំកំចាត់ស្មៅបាចសាច
លើស្លឹក និងកួរស្រូវ។



មិនត្រូវបាញ់ថ្នាំកំចាត់
ស្មៅនៅដំណាក់កាល
ស្រូវទុំឡើយ



## គ្រោះថ្នាក់!

● ត្រូវដឹងថា ថ្នាំកំចាត់ស្មៅ អាចឲ្យស្រូវមិនលូតលាស់(ក្រិន) ឬស្លឹកស្រូវងាប់ ហើយគុណភាពគ្រាប់ស្រូវធ្លាក់ចុះ ប្រសិនបើល្បាយថ្នាំកំចាត់ស្មៅច្រើនពេក។

● ត្រូវប្រុងប្រយ័ត្ន មិនត្រូវបាញ់ថ្នាំលើដំណាំស្រូវ ជាពិសេសអំឡុងពេលដំណាក់កាលស្រូវទុំ បន្ទាប់ពីចេញកួរ។

# ថ្នាំកំចាត់ស្មៅសំរាប់ដំណាំស្រូវដែលអាចរកបានក្នុងទីផ្សារកម្ពុជា

| | | | | | |
|---|---|---|---|---|---|
| |  |  |  |  |  |
| ឈ្មោះថ្នាំ | ណូមីនី/Nominee 10SC | ប៊ីសូណា/BISONA 100SC | អស់កង្វល់/NO WORRY 100SC | ស្រែអស់ស្មៅ/Sre ors Smao | បាយ័នស្មៅ/Bayon Smao |
| គីមីសកម្ម | ប៊ីស្ពីរីបាកសូដ្យូម/Bispyribac sodium | | | | |
| មុខសញ្ញាស្មៅ | ឯកវត្សស្មៅ(ស្មៅដែលបញ្ចប់វដ្តជីវិតរបស់ខ្លួនរយៈមួយឆ្នាំ រឺតិចជាង)/Annual Grasses, ស្មៅស្លឹកធំ/Broadleaf Weeds | | | | |
| ព័ត៌មាននៃការប្រើប្រាស់ | •ប្រភេទស្មៅដុះចេញពីដីហើយ/ Post-emergence Type.<br>•សន្ទូង/ពង្រោះសើមៈ ដំណាក់កាលស្មៅមានស្លឹក៣-៥សន្លឹក ឬ៧-១៥ថ្ងៃបន្ទាប់ពីស្ទូង/ព្រោះរួច។<br>•បង្ហូរទឹកចេញមុននិងបាញ់ដើម្បីឲ្យដល់មុខសញ្ញាស្មៅ។ បញ្ចូលទឹកដាក់ស្រែវិញបន្ទាប់ពីបាញ់បាន១-៣ថ្ងៃប្រយោជន៍ដើម្បីទប់ស្កាត់ស្មៅ។<br>•លាយថ្នាំ១០ម.ល ជាមួយទឹក១៦លីត្រ។<br>•អត្រាបាញ់(កំរិតទឹក)ៈ ១៦០លីត្រ -៣២០លីត្រក្នុងផ្ទៃដីមួយហិចតា។.<br>•បាញ់លើស្លឹកស្មៅ(មិនស្រូបពីឫសទេ)។ | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| |  | |  |  |  | |
| ឈ្មោះថ្នាំ | វីថកអូម៉ូន/Vitoxomone | | ពីអានឆ័រ/PYANCHOR 3EC | ស្មៅស្រូវប្រាំង/Smao Srov Prang | អ៊ិចស្ពឺត/Xpert 70WP | |
| គីមីសកម្ម | ប្រូម៉ានីល/ Propanil | 24D | ពីរីបិនហ្សូស៊ីម/Pyribenzoxim | ឃ្វីនក្លរិច/Quinclorac | ហ្វិណូសាប្រប-ប៉េ-អ៊ីទីល/ Fenoxaprop-P-ethyl | ពីរ៉ាហ្សូស៊ុលហ្វូរ៉ុន-អេទី/ Pyrazosulfuron-ethyl |
| មុខសញ្ញាស្មៅ | ឯកវត្សស្មៅ/ Annual Grasses, | ស្មៅស្លឹកធំ/Broadleaf Weeds | ស្មៅបែកក្បាល/ Barnyard Grass ស្មៅស្លឹកធំ/Broadleaf Weeds | ស្មៅទូទៅ/Grasses | ស្មៅ(ស្មៅវា)/ Grasses (Crabgrass) | ស្មៅទូទៅ, ស្មៅស្លឹកធំ Grasses, Broadleaf Weeds |
| ព័ត៌មាននៃការប្រើប្រាស់ | •ប្រភេទស្មៅដុះចេញ | 2.4-D ស្រូបពីស្លឹក ដើម និងឫសរបស់ស្មៅ។ | •ប្រភេទស្មៅដុះចេញ | | | |

a

# ជំពូក ២

# មូលដ្ឋានគ្រឹះនៃក្សេត្រសាស្ត្រ សំរាប់អ្នកបង្រៀនកសិកម្ម







# បរិស្ថានគីមី & សរីរាង្គក្នុងដី

## អាស៊ីតដី(PH)

ភាពបន្សាំ និងការចូលចិត្ត របស់ដំណាំចំពោះPHដី

(*PH : Potential of Hydrogen)




## មមោក(ការរលួយនៃដំណាំ)ដំណើរការក្នុងដីយ៉ាងដូចម្តេច?



ប្រសិទ្ធផលនៃកំប៉ុស្តិ៍រុក្ខជាតិ

| សមត្ថភាពចាប់យកទឹករបស់ដីកើនឡើង (= ធន់ទ្រាំខ្លាំងទប់ទល់និងភាពរាំងស្ងួត) | សមត្ថភាពចាប់យកសារធាតុជីអាចកើនឡើង(= សារធាតុចញ្ចឹមនៅបានយូរក្នុងដី) | អាសូតនិងធ្វើសកម្មភាពយ៉ាងយឺតនៅក្នុងដី។ | ធ្វើឲ្យដីទន់ |
|---|---|---|---|
|  |  |  |  |









## "ជីកំប៉ុស្តិ៍"

### ដូចជាសម្ភារៈសរីរាង្គ

ជីកំប៉ុស្តិ៍គឺជាសម្ភារៈសរីរាង្គល្អបំផុត(ប្រសិនបើវាត្រូវបានកែច្នៃឲ្យបានសមស្រប) សំរាប់ធ្វើឲ្យប្រសើរឡើងនៃបរិស្ថានដីក្នុងល័ក្ខខ័ណ្ឌគីមី/សរីរ:សាស្រ្ត/ជីវសាស្រ្ត។

| កំប៉ុស្តិ៍ | លក្ខណៈ និងប្រសិទ្ធផល | កំណត់សំគាល់ក្នុងការប្រើប្រាស់ |
|---|---|---|
| អាចម៍សត្វ | ●កំរិតN.P.Kគឺខ្ពស់ខ្លាំងបើធៀបទៅនិងសម្ភារៈរុក្ខជាតិ។<br>●ប្រសិទ្ធផលតិចសំរាប់ការធ្វើឲ្យប្រសើរឡើងនៃបរិស្ថានសរីរៈសាស្រ្តដី | ●ការបាចអាចម៍សត្វស្រស់ៗមុន និងអំឡុងពេលដាំដុះគួរតែជៀសវាងដោយសារការបង្កើតឡើងនៃឧស្ម័នអាម៉ូនីញាក់នៅអំឡុងពេលដំណើរការបំលែងកំប៉ុស្តិ៍។<br>●កំរិតជាតិអាសូតខ្ពស់គួរតែពិចារណា និងគណនាឲ្យបានត្រឹមត្រូវនៅពេលបាចជីគីមីដូចជាDAP & UREA។ វាបណ្តាលឲ្យបាចជាតិអាសូតលើសចំណុះ។<br>●ជីកំប៉ុស្តិ៍ត្រូវតែបាចពង្រាយឲ្យបានស្មើរក្នុងស្រែដើម្បីបញ្ចៀសការដុះលូតលាស់របស់ដំណាំមិនបានស្មើរល្អ។ |
| សម្ភារៈរុក្ខជាតិ | ●កំរិតN.P.Kទាប។<br>●ប្រសិទ្ធផលខ្លាំងសំរាប់កែលំអនៃល័ក្ខខ័ណ្ឌសរីរៈសាស្រ្តដីដូចបានបង្ហាញក្នុងរូបភាពខាងលើ។ | ●ប្រសិនមិនបានបាចប្រភពអាសូតដូចជាអាចម៍សត្វទេនោះ កត្តាកង្វះជាតិអាសូតនិងកើតឡើង ដោយសារថាជាតិអាសូតត្រូវការប្រើប្រាស់ខ្លាំងដោយមីក្រូសរីរាង្គដើម្បីបំលែងសម្ភារៈរុក្ខជាតិឲ្យទៅជាកំប៉ុស្តិ៍.. |

### កំរិតប៉ាន់ប្រម៉ាណ(%)នៃសមាសធាតុជី

| សម្ភារៈសរីរាង្គ | អាសូត (N) | ផូស្វាត (P) | ប៉ូតាស្យូម (K) |
|---|---|---|---|
| អាចម៍មាន់ | 2.5% | 6.5% | 3.5% |
| អាចម៍ជ្រូក | 3.0% | 5.0% | 2.5% |
| អាចម៍គោ | 1.0% | 1.0% | 1.5% |
| ចំបើង | 0.4% | 0.2% | 1.7% |

# វត្ថុធាតុសំខាន់ៗទាំង១៦ចំបាច់សំរាប់ការលូតលាស់របស់ដំណាំស្រូវ និងរុក្ខជាតិ

C H O
ខ្យល់




## វត្ថុធាតុចម្បងៗទាំង៣

| N | P | K |
|---|---|---|
| អាសូត | អាស៊ីដផូស្វ័រិក | ប៉ូតាស្យូម |

## វត្ថុធាតុខ្នាតកណ្តាលទាំង៣

| S | Ca | Mg |
|---|---|---|
| ស្ពាន់ធ័រ | កាល់ស្យូម | ម៉ាញ៉េស្យូម |




ជីដែលអាចជឿជាក់បានគឺបង្ហាញពីវត្ថុធាតុតូចៗ និងកំរិត(ភាគរយ)របស់វាលើការ៉ុងៗ

## វត្ថុធាតុតូចៗ(មីក្រូវត្ថុធាតុ)ទាំង៧

| Fe | Mn | B |
|---|---|---|
| ដែក | ម៉ង់ហ្គាណែស | ប៊ូរ៉ុន |

| Zn | Mo | Cu | Cl |
|---|---|---|---|
| ស័ង្កសី | ម៉ូលីបដិនញ៉ូម | ទង់ដែង | ក្លរីន |

# សកម្មភាព និងមុខងាររបស់វត្ថុធាតុជី

| ផ្នែក | វត្ថុធាតុ | មុខងារចម្បងៗ | រោគសញ្ញានៃការកង្វះសារធាតុចិញ្ចឹម | រោគសញ្ញានៃការប្រើប្រាស់ជីលើចំណុះ |
|---|---|---|---|---|
| វត្ថុធាតុ ចម្បងៗ | **អាសូត (N)** | ដំណាំស្រូបយកជីវជាតិអាសូតក្នុងទម្រង់អសរីរាង្គនៃអាម៉ូញ៉ូម ($NH_4$) និងអាស៊ីដនីត្រាត ($NO_2$, $NO_3$)ពីឫស ហើយសំយោគអាស៊ីដអាមីណូ និងប្រូតេអ៊ីន។ អាសូតក៏ធ្វការងារបង្កើតក្លរ៉ូហ្វិល(ជាលិកាដំណាំដ៏ចាំបាច់សំរាប់ការសំយោគពន្លឺព្រះអាទិត្យ), អង់ស៊ីម និងអ័រម៉ូនដែលមានទំនាក់ទំនងយ៉ាងស៊ីជម្រៅនៃការលូតលាស់របស់ដំណាំ។ ប្រសិទ្ធផលចម្បងនៃអាសូតគឺមានដូចតទៅនេះ;<br>**·ពង្រីកដើម & ស្លឹក, អភិវឌ្ឍន៍ឫស និងធ្វើឲ្យពណ៌ស្លឹកកាន់ខៀវ។** | ·ការលូតលាស់យឺត និងចុះថយចំនួនគុម្ព<br>·ពណ៌ស្លឹកសាកទៅជាពណ៌លឿង<br>·ថយចុះទិន្នផល និងគុណភាពទាប | ·ស្លឹក និងដើមប្រែជាខៀវក្រមៅ ទន់ខ្លាំង<br>·រាំងស្ទះការចេញផ្កា និងផ្លែ<br>·បណ្តាលឲ្យលូតលាស់ដើម ស្លឹកលើចំនួន និងបែកគុម្ពច្រើនពេក ដែលធ្វើឲ្យខ្សោយដែលមិនអាចធន់និងការដួលរំលំ និងឆ្លងជំងឺបាន។<br>·ជាហេតុបណ្តាលឲ្យពន្យាការទុំ។ |
| | **អាស៊ីដផូស្វ័រីក (P)** | **·ជម្រុញផ្កា និងផ្លែ**<br>·ពន្លឿនការលូតលាស់របស់ដំណាំ<br>·ពន្លឿនការអភិវឌ្ឍឫស និងការលូតលាស់របស់វា<br>·បង្កើនចំនួនដើម ឫស និងស្លឹក<br>·បង្កើនចំនួនផ្លែ(គ្រាប់) និងគុណភាព | ·ចុះថយចំនួនកូម្ព និងផ្កា<br>·ពន្យាការចេញផ្កា និងផ្លែ<br>·ធ្វើឲ្យឫសលូតលាស់ខ្សោយ<br>·ពណ៌ជាយស្លឹកឡើងពណ៌ក្រមៅ ឬពណ៌ស្វាយ | ·វាអាចជាឧបសគ្គយ៉ាងធ្ងន់ បន្តែឆាប់បញ្ចប់ការលូតលាស់ ហើយធ្វើឲ្យឆាប់ទុំ និងទិន្នផលទាប។<br>·ប្រើប្រាស់ជីលើសចំណុះអាចបណ្តាលឲ្យខ្វះសារធាតុស័ង្កសី(Zn), ដែក(Fe) និងម៉ាញ៉េស្យូម(Mg)។ |
| | **ប៉ូតាស្យូម (K)** | **·ជម្រុញការអេភិវឌ្ឍឫស និងការលូតលាស់**<br>**·ពង្រឹងដំណាំទប់ទល់និងជំងឺផ្សេងៗ**<br>·ពង្រឹងឫស និងដើមទប់ទល់និងជំងឺផ្សេងៗ<br>·ជម្រុញផ្កា និងផ្លែ | ·រសជាតិ និងផលធ្លាក់ចុះ<br>·ការលូតលាស់របស់ឫសតិច និងបណ្តាលឲ្យឫសស្អុយរលួយ | ·រាំងស្ទះការស្រូបយកសារធាតុម៉ាញ៉េស្យូម និងកាល់ស្យូម។ |
| វត្ថុធាតុ ខ្នាតកណ្តាល | កាល់ស្យូម (Ca) | ·វត្ថុធាតុដ៏ចាំបាច់សំរាប់ចងភ្ជាប់ជាលិកាដំណាំមួយទៅមួយទៀត និងសំរាប់ឲ្យ លូតលាស់របស់ឫសមានសុខភាពល្អ<br>·បន្សាបជាតិអាស៊ីដដី(PH) | ·ពណ៌ស្លឹកថ្មីបប្រែជាពណ៌លឿងចាប់ពីចុងស្លឹក ហើយងាប់តែប្តង។ | ·ជាហេតុបណ្តាលឲ្យខ្វះសារធាតុប៊ូរ៉ុន(B), ម៉ាញ៉េស្យម(Mn), ស័ង្កសី(Zn) និងដែក(Fe)។ |
| | ម៉ាញ៉េស្យូម (Mg) | ·ចាំបាច់សំរាប់ជម្រុញការសំយោគពន្លឺព្រះអាទិត្យ<br>·ជំនួយការងាររបស់អាស៊ីដផូស្វ័រីក<br>·ម៉ាញ៉េស្យូម( Mg) គឺជាវត្ថុធាតុមួយដ៏សំខាន់មានក្លរ៉ូហ្វិលក្នុងស្លឹកដែលជម្រុញ ការងារសំយោគពន្លឺព្រះអាទិត្យ។ | ·ពណ៌ស្លឹកចាស់ប្រែជាពណ៌លឿងចាប់ពីជាយចុងស្លឹក | ·ជាហេតុបណ្តាលឲ្យខ្វះសារធាតុប៊ូរ៉ុន(B), ម៉ាញ៉េស្យម(Mn) និងស័ង្កសី(Zn)។ |
| | ស្ពាន់ធ័រ (S) | ·ដឹកនាំការលូតលាស់របស់ដំណាំ<br>·មានទំនាក់ទំនងយ៉ាងស៊ីជម្រៅដល់អុក្ស៊ីទ និងឌីអុក្ស៊ីទខាងក្នុងដំណាំ<br>·កង្វះខាតស្ពាន់ធ័របណ្តាលឲ្យដំណាំលូតលាស់មិនគ្រាប់គ្រាន់ | ·ពណ៌ស្លឹកប្រែជាពណ៌លឿង ជាពិសេសឃើញមានច្រើនលើស្លឹកចាស់។ | ·បណ្តាលឲ្យកើតមានអុកស៊ីដដី |
| វត្ថុធាតុ តូចៗ (Trace Element) | ដែក (Fe) | ·វត្ថុធាតុដ៏ចាំបាច់ត្រូវការក្នុងដំណើរការនៃការរៀបចំឲ្យមានក្លរ៉ូហ្វិលក្នុងដំណាំ (*ក្លរ៉ូហ្វិលគឺជាសារធាតុបង្ករឲ្យមានស្លឹកបៃតង និងចាំបាច់សំរាប់សំយោគពន្លឺព្រះអាទិត្យ)។ | ·ពណ៌ស្លឹកឡើងប្រែជាពណ៌លឿង និងស។ | ·រាំងស្ទះការស្រូបយកសារធាតុអាស៊ីដផូស្វ័រីក(P)<br>·ឫទៅជាស្អុយរលួយ<br>·ពណ៌ស្លឹកប្រែពណ៌ជាពណ៌សវិញ។ |
| | ម៉ាហ្គាណែស (Mn) | ·បង្កើតអង់ស៊ីមមានទំនាក់ទំនងដល់ទម្រង់ប្រូតេអ៊ីន និងដង្ហើមរបស់ដំណាំ<br>·សំយោគក្លរ៉ូហ្វិលចាំបាច់សំរាប់សំយោគពន្លឺព្រះអាទិត្យ<br>·សំយោគវីតាមីនក្នុងដំណាំ | ·អុជពណ៌លឿង ឬត្នោតកើតមានលើស្លឹក | — |
| | ប៊ូរ៉ុន (B) | ជម្រុញការអភិវឌ្ឍនៃពន្លកផ្កាថ្មីៗ និងការលូតលាស់នៃឫស | ·ចេញផ្កាក្រពុំតិច<br>·ការលូតលាស់ឫសតិច | ·ពណ៌ស្លឹកប្រែជាពណ៌លឿង និងត្នោត |
| | ស័ង្កសី (Zn) | ·ធ្វើការដើម្បីអភិវឌ្ឍន៍ស្លឹកថ្មីៗ<br>·ជាតិដែក(Zn)មានទំនាក់ទំនងទៅនិងសកម្មភាពលូតលាស់របស់អ័រម៉ូនដំណាំ | ·ស្លឹកតូចៗ និងផ្លាស់ប្តូរទ្រង់ទ្រាយ | ·ពណ៌ស្លឹកដុះថ្មីប្រែជាពណ៌លឿង និងមានអុជ |
| | ម៉ូលីដិនញ៉ូម (Mo) | ·វត្ថុធាតុសំខាន់ៗសំរាប់ការងារបំលែងអាសូត(មីក្រូសរីរាង្គ)ទៅជាការបំលែងសមស្របនៃអាសូតខ្យល់។<br>·ការសំយោគវីតាមីនក្នុងដំណាំ | ·អុជពណ៌លឿងនិងកើតលើស្លឹក ហើយស្លឹកធ្លាក់ចុះ។ | — |
| | ទង់ដែង (Cu) | ·ទង់ដែង(Cu)មានទំនាក់ទំនងសកម្មភាពនៃអ៊ុកស៊ីដអង់ស៊ីម<br>·ការចងក្រងជាក្លរ៉ូហ្វិល | ·ពណ៌ស្លឹកប្រែជាលឿង និងសហើយស្លឹកធ្លាក់ចុះ។ | ·ការលូតលាស់ឫសខ្សោយ |
| | ក្លូរីន (Cl) | ·ក្លូរីន(Cl)គឺជាវត្ថុធាតុសំខាន់សំរាប់សកម្មភាពសំយោគពន្លឺព្រះអាទិត្យ។ | · ស្លឹកងាប់ចាប់ចុងមក | ·ឫសស្អុយរលួយ |


វដ្តនៃអាសូតក្នុង
លក្ខខណ្ឌធម្មជាតិ
N2
N2
រុក្ខជាតិជាបន្លែ
ចំណាប់
អាសូតដោយ
ឫសមានបាក់
តេរីពកតូចៗ
N2
N2
N2
UREA
CH4N2O
●សាកសពសត្វងាប់
●លាមកសត្វ, មាន់ ទា
●ចំបើង ស្មៅ ស្លឹកឈើ
●មមោក
អាសូតក្នុង
ទម្រង់សរីរាង្គ
អាសូតក្នុង
អសរីរាង្គ
អាម៉ូញ៉ូម
NH4+-N
នីទ្រីត
NO2--N
នីត្រាត
NO3--N
គុណប្រយោជន៍នៃមុខងារមីក្រូសរីរាង្គគឺដើម្បីបំលែងសម្ភារៈសរីរាង្គទៅជាទម្រង់អសរីរាង្គវិញ។
គុណប្រយោជន៍នៃមុខងារមីក្រូសរីរាង្គគឺដើម្បីបំលែងអាម៉ូញ៉ូមទៅជានីទ្រីត និងនីត្រាតវិញ។


ការបំលាស់ប្តូរនៃអាសូត និងការធ្វើចលនារបស់វាក្នុងដី
អាម៉ូញ៉ូម
$NH_4^+$-N
នីត្រាត
$NO_3^-$-N
ដីខ្ពង់រាប
ដីស្រែ
$N_2$
$N_2$
$N_2$
$NO_3^-$
$NH_4^+$
ស្រទាប់អុកស៊ីដ
ទឹក
ស្រទាប់អុកស៊ីដ
ស្រទាប់ឱអុកស៊ីដ
អង្គធាតុស្អិតដី
អង្គធាតុស្អិតដី
នៅពេលអង្គធាតុស្អិតដីមានអ៊ីយ៉ុងដក និង NO3-មានអ៊ីយ៉ុងដក ហើយអង្គធាតុទាំងពីនិងច្រានគ្នាចេញ។ យ៉ាងណាមិញ NO3គឺងាយនិងដោះលែង(ចាកចេញ)ចូលក្នុងទឹក និងខ្យល់។ ដំណាំខ្ពង់រាបស្រូបយកសំខាន់អាសូតជាទម្រង់ NO3វិញ។
អង្គធាតុស្អិតដី (អ៊ីយ៉ុង– ) និង NH4(អ៊ីយ៉ុង+)ទាញគ្នាទៅវិញទៅមកដូចមេដែក។ យ៉ាងណាមិញ NH4នៅជាប់បានយូរក្នុងដី និងត្រូវបានស្រូបយកដោយឫសដំណាំស្រូវដូចសារធាតុអាសូតដែរ

# ការរៀបចំថ្នាលសំណាបតាមវិធីសាស្ត្រដាប៉ុក





# របៀបធ្វើថ្នាលសំណាប "ដាប៉ុក"



①

<u>ការរៀបចំសម្ភារៈធ្វើថ្នាលដែលចាំបាច់</u>

1. ស្រទប និងស្លឹកចេក
2. ដី និងលាមកសត្វស្ងួត(មិនត្រូវប្រើលាមកស្រស់ទេ) ឬជីកំប៉ុស្តិ៍ដែលពុកផុយបានល្អ។
3. ធ្យូងអង្កាម (មិនមែនផេះ)
4. កំរិតត្រូវលាយដី៤០% ជីលាមកសត្វ(ឬជីកំប៉ុស្តិ៍) ៣០% ធ្យូងអង្កាម៣០%។
5. ប្រសិនបើមិនមានលាមកសត្វ ឬជីកំប៉ុស្តិ៍ លាយតែដី (៥០%) និងធ្យូងអង្កាម(៥០%)ក៏បានដែរ។





②

<u>ការធ្វើជាទម្រង់</u>

1. ធ្វើស៊ុមខាងក្រៅដោយប្រើបំណែកនៃស្រទបចេក។
2. ស្រទបចេកត្រូវគៀបដោយបង្គោលឫស្សី
3. ដាក់តំរៀបស្លឹកចេកក្រាលឲ្យពេញខាងក្រោម។ (កម្រាលកៅស៊ូអាចប្រើជំនួសស្រទបចេកបាន ប៉ុន្តែវាត្រូវចំណាយបន្ថែមសំរាបទិញវា)។

**ទំហំថ្នាលសំណាបចាំបាច់សំរាប់មួយហិចតាគឺ ;**

1plot =10 ㎡（1 m×10m）＝0.25ha

សំរាបស្ទូង1 ហ.ត, 5ថ្នាលគឺតម្រូវឲ្យធ្វើ។



③

<u>ការរៀបចំថ្នាល</u>

1. ដាកពង្រាយល្បាយដី ដែលបានលាយហើយឲ្យបានស្មើរ កម្រាសប្រហែល5cm និងបង្ហាប់ផ្ទៃខាងលើថ្នមៗ។
2. ស្រោចទឹកដើម្បីឲ្យល្បាយដីមានសំណើម។

(*មិនត្រូវស្រោចទឹកច្រើនពេករហូតដល់ហៀរហូរលើផ្ទៃថ្នាល)។



<u>សាបគ្រាប់ស្រូវ</u>

1. ចំនួនគ្រាប់ស្រូវត្រូវសាបគឺ 0.8kg / ㎡ (1m×1m),
2. ចំនួនគ្រាប់ស្រូវចាំបាច់សំរាប់មួយហិចតា; 8kg /plot(1m×10 m＝10 ㎡)×5 plots =40kg/ha

④



<u>ការគ្របពីលើ</u>

1. បន្ទាប់ពីសាបរួច ត្រូវគ្របល្បាយដីលាយពីលើស្តើងៗហើយ ត្រូវស្រោចទឹកម្តងទៀត ។

⑤



<u>ការពិនិត្យសំណាប</u>

1. បន្ទាប់ពីគ្រាប់ដុះ ត្រូវពិនិត្យពណ៌ស្លឹកអោយបានល្អិតល្អន់។
2. **ស្រោចទឹកឲ្យបានគ្រប់គ្រាន់យ៉ាងហោចណាស់៥ដងក្នុងមួយថ្ងៃ។**

⑥



<u>ការស្ទូង</u>

1. **អាយុកាលសំណាបពី១២ទៅ១៤ថ្ងៃគឺ** ពេលល្អបំផុតសំរាប់ការស្ទូង

⑦



<u>លក្ខខណ្ឌតម្រូវការទឹកក្នុងស្រែ</u>

1. ករណីកំរិតទឹកក្នុងស្រែខ្ពស់ សំណាបដាប៉ុកមិនអាចស្ទូងបានឡើយ។
2. រូបភាពខាងលើគឺជាកំរិតទឹកល្អបំផុតសំរាប់ការស្ទូង។



<u>គំរូនៃករណីបរាជ័យ</u>

កង្វះខាតទឹកធ្វើឲ្យសំណាបឆាប់ងាប់ ស្លឹកប្រែក្លាយជាលឿងទៅស (ចូរកុំឲ្យមានកំហុសក្នុងការកំណត់ប្រភេទជំងឺ)

***មិនត្រូវខកខានក្នុងការស្រោចទឹកឲ្យបានគ្រប់គ្រាន់យ៉ាងហោចណាស់៥ដងក្នុងមួយថ្ងៃ។**

a

បោះពុម្ពផ្សព្វផ្សាយនៅក្នុងខែធ្នូ ឆ្នាំ២០១៤